អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០

# សេចក្តីប្រកាសព័ត៌មាន
# អង្គជំនុំជម្រះតុលាការកំពូលបញ្ចប់សំណុំរឿងប្រឆាំងនឹង អោ អាន នៅចំពោះមុខ អ.វ.ត.ក

ថ្ងៃនេះ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបញ្ចប់សំណុំរឿងប្រឆាំង អោ អាន នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។

បន្ទាប់ពីមាន “បណ្តឹងសាទុក្ខជាបន្ទាន់ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង” របស់សហព្រះរាជអាជ្ញាអន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយទទ្បីករណ៍នានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសេចក្តីសម្រេចនៅថ្ងៃនេះ។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា៖ “បើទោះបីជាមានការឯកភាពគ្នា ពាក់ព័ន្ធនឹងចំនួនជនរងគ្រោះជាច្រើននៅក្នុងភូមិភាគកណ្តាល” នៃកម្ពុជាប្រជាធិបតេយ្យក៏ដោយ “ក៏ពុំមានការឯកភាពគ្នាឡើយ បន្ទាប់ពីរយៈពេលដប់បីឆ្នាំនៃកិច្ចស៊ើបសួរដែលថា អោ អាន ស្ថិតក្នុងយុត្តាធិការរបស់ [អ.វ.ត.ក]”។ ដោយបដិសេធ បណ្តឹងសាទុក្ខភ្លាមៗរបស់ សហព្រះរាជ អាជ្ញាអន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា៖ “ក្នុងករណីដែលពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលជាក់លាក់ និងអាចអនុវត្តបាននោះ ដូចនេះរឿងក្តីប្រឆាំងនឹង អោ អាន ត្រូវបញ្ចប់នៅចំពោះមុខ អ.វ.ត.ក”។

សេចក្តីសម្រេចនេះត្រូវបានផ្សព្វផ្សាយនៅលើតំណភ្ជាប់ដូចខាងក្រោម៖
https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/E004_2_1_1_2_KH.pdf

សេចក្តីប្រកាសព័ត៌មាននេះត្រូវបានផ្សព្វផ្សាយដោយផ្នែកកិច្ចការសាធារណៈ អនុលោមតាមវិធាន ៩(៤) និង ២១ (១) (គ) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដើម្បីចែកជូនព័ត៌មានដល់សាធារណជន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក នេត្រ ភក្ត្រា**
ប្រធានផ្នែកកិច្ចកការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦
អ៊ីមែល៖ neth.pheaktra@eccc.gov.kh